CITY OF LONG BEACH

PRESS RELEASE

**សេចក្តីប្រកាសព័ត៍មាន**

ថ្ងៃទី 22 ខែកុម្ភៈ ឆ្នាំ 2021
ទំនាក់ទំនង ៖ ជូដេត លួង (Judeth Luong) អ្នកគ្រប់គ្រងការិយាល័យសុខាភាពបរិស្ថាន នៃនាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស, 562.570.4104, Judeth.Luong@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# ឆ្នេសមុទ្រ ឡុងប៊ិច ត្រូវបានបិទ ជាបណ្តោះអាសន្ន ដោយសារបញ្ហាហៀរទឹកលូ ។

វេជ្ជ. អានីសសា ដាវីស (Anissa Davis) មន្ត្រីសុខាភិបាល ក្រុងឡុងប៊ិច បានចេញបទបញ្ជា ទីតាំងលេងទឹកនានា នៅប៉ែកខាងលិខ ប៊ែលម៉ុន ភៀ (Belmont Pier) ក្នុងឡុងប៊ិច បិទមិនឱ្យប៉ះពាល់ទឹក ជាបណ្តោះអាសន្ន ដោយសារបញ្ហាហៀរទឹកលូ ។ ច្បាប់រដ្ឋ តម្រូវឱ្យបិទដំណើរការ ជាបណ្តោះអាសន្ន និងមានបិទផ្សាយដំណឹង នៅតាមតំបន់ឆ្នេរ ដែលជួបបញ្ហានេះ ឱ្យប្រកាន់ការប្រុងប្រយ័ត្នខ្ពស់ រហូតទាល់តែគុណភាពទឹក អាចបំពេញបាន តាមលក្ខខណ្ឌតម្រូវ របស់រដ្ឋ ។

យោងតាមរបាយការណ៍ ដែលទទួលបានព្រឹកមិញនេះ ពីការិយាល័យសេវាពេលមានគ្រោះអាសន្ន របស់អភិបាល, ទឹកលូ ប្រមាណ 26,241 ហ្គាឡុង បានហៀរចូលទៅក្នុងទន្លេ ឡូស អ៊ែនជីឡេស កាលពីថ្ងៃទី 22 ខែកុម្ភៈ ឆ្នាំ 2021 ។ ការហៀរទឹកលូ បានកើតមានឡើង នៅទីក្រុងឡូស អ៊ែនជីឡេស និងត្រូវបានបង្ករឡើង ដោយសកម្មភាពសាងសង់ ដើម្បីរក្សាឱ្យបាន បណ្តាញលូ ចំបង 48 អ៊ិញ ។

ក្រុមអធិការកិច្ចសុខភាពគុណភាពទឹក សម្រាប់ការកំសាន្ត របស់នាយកដ្ឋានសុខាភិបាល នៃសាលាក្រុងឡុងប៊ិច កំពុងធ្វើការត្រួតពិនិត្យមើលគុណភាពទឹក នៅទីតាំងនានា តាមបណ្តោយឆ្នេរសមុទ្រ ដែលរងផលប៉ះពាល់ ។ ការត្រួតពិនិត្យទឹកនេះ នឹងបន្តដំណើរការ រហូតទាល់តែឃើញលទ្ធផល អនុលោមបានតាមបទដ្ឋានគុណភាពទឹក របស់រដ្ឋ ។

ឡុងប៊ិច មានឆ្នេរសមុទ្រសាធារណ: ប្រវែងប្រមាណ ប្រាំពីរម៉ៃយ៍ ។ ដើម្បីការពារសុវត្ថិភាពសាធារណ: សំណាកទឹក ត្រូវបានប្រមូលយក ជាប្រចាំសប្តាហ៍ និងត្រូវធ្វើតេស្ត ជាប្រចាំ ដើម្បីតាមដានកម្រិតបាក់តេរី ។ ដើម្បីសុវត្ថិភាពរបស់ពួកគេ សហគមន៍ត្រូវបានលើកទឹកចិត្តឱ្យយកចិត្តទុកដាក់ ពិនិត្យមើលគ្រប់សញ្ញាដាស់តឿន មានបិទផ្សាយ នៅតាមឆ្នេរសមុទ្រ ។

សម្រាប់ស្ថានភាព ចុងក្រោយបំផុត នៃគុណភាពទឹក នៅឆ្នេរកំសាន្ត ឡុងប៊ិច, សាធារណជនអាចទូរសព្ទទៅ បណ្តាញ ទាន់ហេតុការណ៍ របស់ផ្នែកទឹក ដែលមានលេខ (562) 570-4199 ឬ ចូលទៅ http://www.longbeach.gov/beachwaterquality បាន ។

សំណួរ ពីប្រព័ន្ធផ្សព្វផ្សាយ អាចបញ្ជូនទៅ ជូដេត លួង (Judeth Luong) អ្នកគ្រប់គ្រងការិយាល័យសុខាភាពបរិស្ថាន នៃនាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស ។ 562.570.4104, Judeth.Luong@longbeach.gov.

# # #